# ការកែប្រែថ្មីៗ របស់ផែនការ

## ក្រុមប្រឹក្សាភិបាលអប់រំ

## ថ្ងៃទី7 ខែឧសភា ឆ្នាំ2025

បទបង្ហាញ

# ផែនការគ្រប់គ្រង និងគណនេយ្យភាពប្រចាំមូលដ្ឋាន


ផែនការគ្រប់គ្រង និងគណនេយ្យភាពប្រចាំមូលដ្ឋាន (LCAP) ជាផែនការរបស់មន្ទីរអប់រំដែលមានរយៈពេលបីឆ្នាំ និងត្រូវធ្វើការកែប្រែជារៀងរាល់ឆ្នាំ តាមរយៈការប្រឹក្សាពិគ្រោះ និងការចូលរួមជាមួយសហគមន៍ ហើយវាមានរៀបរាប់ក្នុង គោលដៅ កម្មវិធី និងសេវាកម្មជាច្រើន និងការចំណាយដែលបានស្នើឡើង ក្នុងមូលនិធិរបស់រដ្ឋ LCFF ដើម្បី៖

- គាំទ្រដល់លទ្ធផលសិក្សាជាវិជ្ជមានរបស់សិស្ស ដែលឆ្លើយតបទៅនឹងអាទិភាពជាច្រើននៅកម្រិតរដ្ឋ និងនៅមូលដ្ឋាន។
- បិទគម្លាតសមធម៌ សម្រាប់ក្រុមសិស្សគោលដៅរបស់រដ្ឋ៖ សិស្សរៀនភាសាអង់គ្លេស សិស្សដែលគ្រួសារមានចំណូលទាប និងសិស្សដែលស្ថិតក្រោមការថែទាំបណ្តោះអាសន្ន



# ថវិកាសរុបបានពីចំណូលមូលនិធិប៉ាន់ស្មានជាទូទៅរបស់ LBUSD សម្រាប់ ឆ្នាំ2025-26

**$1.1ពាន់លាន** (នៅរបាយការណ៍អន្តរកាលទីពីរ - ខែមីនា ឆ្នាំ2025)




ប្រាក់ជំនួយនៅមូលដ្ឋាន
ចំនួនត្រូវតែទទួលបាន
និងប្រាក់ចំណូល

កម្មវិធីឧបត្ថម្ភពីសហពន្ធ $40លាន

កម្មវិធីអប់រំពិសេស -ច្បាប់អប់រំជនពិការអាមេរិក (IDEA) $15.5លាន

កម្មវិធីអប់រំពិសេស ក្រោមច្បាប់ AB602 $67លាន
កម្មវិធី STRS តំណាងក្នុងចំនួន $40លាន
កម្មវិធីពង្រីកឱកាសសិក្សា(ELOP) $31លាន
ជំនួយពីលុយលក់ឆ្នោតជាតិ $16លាន
កម្មវិធីសិក្សាក្រោយម៉ោង $12លាន
កម្មវិធីសិក្សាសិល្បៈ និងភ្លេង $10លាន
កម្មវិធីអប់រំអាជីពបច្ចេកទេស & កម្លាំងការងារ $6លាន

LCFF $828.5លាន

**CTE** កម្មវិធីអប់រំអាជីពបច្ចេកទេស | **ELOP** កម្មវិធីពង្រីកឱកាសសិក្សា Program | **IDEA** ច្បាប់អប់រំជនពិការអាមេរិក | **LCFF** រូបមន្តគ្រប់គ្រងមូលនិធិនៅមូលដ្ឋាន | **STRS** ប្រព័ន្ធសោធន៍និវត្តន៍របស់រដ្ឋ

# កាលវិភាគសម្រាប់ការចូលរួម ឆ្នាំ2024-2025

## ដំណាក់កាល ទី1
ខែកុម្ភៈ-មីនា 2025

### ប្រមូលមតិយោបល់ សហគមន៍ដើម្បីធ្វើថវិកា

ចាប់ផ្តើមធ្វើមតិតាម **ThoughtExchange**៖

- **ការផ្លាស់ប្តូរគំនិតគ្នាទៅវិញទៅមក**

**ការប្រជុំចូលរួមផ្សេងៗ** ដែលនឹងដាក់ប្រកាសជូនតាម៖ www.lbschools.net/LCAP

ចែកចាយ**ការកែប្រែថ្មីជារៀងរាល់ខែ** ទៅកាន់គ្រួសារ និងបុគ្គលិក

## ដំណាក់កាល ទី2
ខែមេសា-ឧសភា 2025

### បន្តទទួលមតិយោបល់ និងធ្វើពង្រាង ផែនការ LCAP

បុគ្គលិក នឹងទំនាក់ទំនងទៅ **ក្រុមប្រឹក្សាជាឪពុកម្តាយផ្សេងៗ** ដើម្បីចែករំលែកនូវលទ្ធផលស្ទង់មតិដំបូងតាម ThoughtExchange

ថវិកាសរុបជាទូទៅ និងខ្លឹមសារផែនការ LCAP នឹងដាក់ប្រកាសជូនជាសាធារណៈ:

ខែឧសភា 2025៖
**សេចក្តីព្រាងផែនការ LCAP** នឹងត្រូវដាក់ប្រកាសជូន និងទទួល**មតិកែលម្អពីសហគមន៍** អំពីសេចក្តីព្រាងរបស់ផែនការ LCAP នោះ

## ដំណាក់កាល ទី3
ខែឧសភា-មិថុនា 2025

### ធ្វើផែនការ LCAP ឱ្យចប់

បុគ្គលិក នឹងបន្តផ្ដិតផ្ដង់កែប្រែលើ **ផែនការ LCAP**

ខែមិថុនា 2025៖
**ការឆ្លើយតប** ចំពោះមតិយោបល់កែលម្អពីសហគមន៍

ក្រុមប្រឹក្សាភិបាលអប់រំ នឹងត្រួតពិនិត្យមើលថវិកា និងផែនការ LCAP **ដើម្បីធ្វើការអនុម័ត**

# ការចូលរួមផ្តល់មតិយោបល់តាម ThoughtExchange

## លើ អាទិភាពជាច្រើន

# សំណួរក្នុងការផ្លាស់ប្តូរយោបល់គ្នា

thoughtexchange


ខណៈពេលដែលយើងធ្វើផែនការ LCAP សម្រាប់ឆ្នាំក្រោយ តើកម្មវិធី សេវាកម្ម ឬជំនួយគាំទ្រអ្វីខ្លះ ដែលអ្នកជឿថា នឹងជះផលប៉ះពាល់ជាងគេបំផុត ទៅលើលទ្ធផលជោគជ័យរបស់សិស្សនៅមន្ទីរអប់រំ LBUSD?





# Thought Exchange

## អ្នកចូលរួម

ខណៈពេលដែលយើងធ្វើផែនការ LCAP សម្រាប់ឆ្នាំសិក្សាក្រោយ តើមានកម្មវិធី សេវាកម្ម ឬជំនួយគាំទ្រអ្វីខ្លះ ដែលអ្នកជឿថា នឹងជះផលប៉ះពាល់ជាងគេបំផុត ដល់លទ្ធផលសិក្សាជោគជ័យ របស់សិស្ស ក្នុងមន្ទីរអប់រំ LBUSD?








យោងតាមគំនិតសរុបក្នុងប្រធានបទនីមួយៗ

# គោលដៅ ទី1៖ ការសិក្សាដែលមានគុណភាពខ្ពស់ សម្រាប់សិស្សទាំងអស់




# គោលដៅ ទី2៖ ការសិក្សាដែលមានគុណភាពខ្ពស់ ដើម្បីសមិទ្ធផលសិក្សាសិស្សអាមេរិកខ្មៅ

ប្រធានបទ៖
**សមិទ្ធផលសិក្សា**
**សិស្សអាមេរិកខ្មៅ**




# គោលដៅ ទី3៖ ការសិក្សាដែលមានគុណភាពខ្ពស់ សម្រាប់សិស្សរៀនភាសាអង់គ្លេស និងសិស្សរៀនភាសាអង់គ្លេសរយៈពេលយូរ

គំនិតវិភាគតាមប្រធានបទ៖ សិស្សរៀនភាសាអង់គ្លេស និងសិស្សរៀនភាសាអង់គ្លេសរយៈពេលយូរ (5)




# គោលដៅ ទី4៖ ការសិក្សាដែលមានគុណភាពខ្ពស់ សម្រាប់សិស្សពិការផ្សេងៗ

## គំនិតវិភាគតាមប្រធានបទ៖ សេវាសម្រាប់កម្មវិធីអប់រំពិសេស (98)



# គោលដៅ ទី5៖ ការសិក្សាដែលមានគុណភាពខ្ពស់សម្រាប់សិស្សដែលគ្មានលំនៅដ្ឋាន និងសិស្សគេជ្រើសចិញ្ចឹមបណ្តោះអាសន្ន

គំនិតវិភាគតាមប្រធានបទ៖ សិស្សដែលគ្មានលំនៅដ្ឋាន និងសិស្សគេជ្រើសចិញ្ចឹមបណ្តោះអាសន្ន




ប្រធានបទ៖
ជំនួយគាំទ្រសម្រាប់សិស្ស
ដែលគ្មានលំនៅដ្ឋាន និង
សិស្សគេជ្រើសចិញ្ចឹមបណ្តោះអាសន្ន

# Thought Exchange
## សេចក្តីសង្ខេបតាមប្រព័ន្ធបញ្ញាសិប្បនិម្មិត (AI)

| អ្នកចូលរួមផ្តល់មតិ | ចំនួនគំនិត | វាយតម្លៃ |
|---|---|---|
| 2,318 | 1,510 | 36,029 |
| Last activity: 0 days ago | 0.7 thoughts / participant | 15.5 ratings / participant |

ចម្លើយតបជាច្រើន បានសង្កត់ធ្ងន់លើ**ការចូលរួមរបស់ឪពុកម្តាយនិងសហគមន៍ កម្មវិធីអប់រំអំពីការប្រឆាំងនឹងគ្រឿងញាន ធនធានព័ត៌មានអំពីសុខភាពផ្លូវចិត្ត** ហើយនិង**ថ្នាក់រៀនដែលមានសិស្សចំនួនតិច**។ ការផ្តល់យោបល់ជាច្រើន រួមមាន **ការបង្កើនមូលនិធិឧបត្ថម្ភសម្រាប់កម្មវិធីសិក្សាសិល្បៈ ភ្លេង កាយសិក្សា កម្មវិធីសិក្សាក្រោយម៉ោង** ហើយនិង**ធនធានព័ត៌មានសម្រាប់សិស្សពិការផងដែរ**។ ដើម្បីលើកកម្ពស់លទ្ធផលសិក្សាជោគជ័យ គឺមានការលើកឡើងនូវ **ការបង្ហាត់គួរ គ្រូបង្រៀនដែលលះបង់ ការអនុវត្តបង្ហាត់តាមថ្នាក់ដែលទំនើប ការត្រៀមលក្ខណៈចូលមហាវិទ្យាល័យ** និង**វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ**។ លើសពីនេះទៀត **មជ្ឈមណ្ឌលសុខុមាលភាពសិស្ស ជំនួយគាំទ្រសម្រាប់តម្រូវការពិសេស** និង**កម្មវិធីអភិវឌ្ឍសង្គម** និង**ការទំនាក់ទំនងខាងអារម្មណ៍** ហើយនិង**ការពង្រឹងសុវត្ថិភាពសាលារៀន** ក៏ត្រូវបានដាក់ជាទិភាពផងដែរ។ ជាចុងក្រោយ ក៏មានការកត់សម្គាល់លើ **ការតស៊ូមតិដើម្បីសមធម៌ក្នុងការសិក្សាអប់រំ គោលនយោបាយដែលរួមបញ្ចូលទាំងអស់** ហើយនិង **ការលើកកម្ពស់ការប្រាស្រ័យទំនាក់ទំនងរវាងសាលារៀន** និង**គ្រួសារ** ផងដែរ។

# អាទិភាពសកម្មជាច្រើន របស់សហគមន៍

1. ការបែងចែកថវិកាទៅតាមសាលារៀន
2. អន្តរាគមន៍សិក្សាអក្សរសាស្ត្រ
3. ការថែទាំសុខភាព/មជ្ឈមណ្ឌលសុខុមាលភាព
4. សេវាកម្មជំនួយគាំទ្រដល់សិស្ស
5. ការបង្កាត់មេរៀនមូលដ្ឋានគោលដៅលមានគុណភាព
6. ជំនួយគាំទ្រដល់សិស្សរៀនភាសាអង់គ្លេស
7. សមិទ្ធិផលសិក្សា សិស្សអាមេរិកខ្មៅ (BSA)
8. វិជ្ជាស្ថាននៃការដឹកនាំ និងកម្មវិធីសិក្សាមហាវិទ្យាល័យ
9. ការស្តារយុត្តិធម៌ឡើងវិញ
10. ជំនួយគាំទ្រដល់សិស្សដែលគ្មានលំនៅដ្ឋាន និងសិស្សគេជ្រើសចិញ្ចឹមបណ្តោះអាសន្ន

**អាទិភាពទាំង 10 គឺមានប្រាក់ឧបត្ថម្ភ នៅក្នុងផែនការ LCAP។**

# ផែនការ LCAP ព្រាង #1


## កំពុងវិវត្តទៅមុខ

# តើមានអ្វីខ្លះ នៅក្នុងផែនការ LCAP នេះ?

ច្បាប់អប់រំ រដ្ឋកាលីហ្វ័ញ្ញា ប្រើប្រាស់គំរូបទដ្ឋានស្តង់ដារ សម្រាប់មន្ទីរអប់រំទាំងអស់ ក្នុងការរៀបចំសរសេរនូវផែនការ LCAP។

សេចក្តីសង្ខេបនៃមាតិកាខ្លឹមសារ របស់គំរូផែនការ LCAP៖

- សេចក្តីសង្ខេបរបស់ផែនការ
- ការទំនាក់ទំនងពាក់ព័ន្ធដល់ដៃគូធ្វើការអប់រំ
- គោលដៅ និង សកម្មភាពជាច្រើន
- ការបង្កើន ឬ ការលើកកម្ពស់ សេវាកម្មសម្រាប់សិស្សគេជ្រើសចិញ្ចឹមបណ្តោះអាសន្ន សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលគ្រួសារមានចំណូលទាប


Local Control and Accountability Plan DRAFT #1 (5/2/25)

The instructions for completing the Local Control and Accountability Plan (LCAP) follow the template.

| Local Educational Agency (LEA) Name | Contact Name and Title | Email and Phone |
|---|---|---|
| LONG BEACH UNIFIED SCHOOL DISTRICT | Dr. Jill Baker, Superintendent | jbaker@lbschools.net 562.997.8240 |

Plan Summary 2025-26

General Information

A description of the LEA, its schools, and its students in grades transitional kindergarten–12, as applicable to the LEA. LEAs may also provide information about their strategic plan, vision, etc.

*Long Beach Unified School District*

***Vision Statement:***

*Graduates of Long Beach Unified School District are future-ready. They are trustworthy, ethical and resilient, and are able to learn, collaborate and adapt to changing circumstances. They act confidently in the service of justice.*

Local Control and Accountability Plan Template Page 1




**សេចក្តីព្រាងនេះ នឹងត្រូវគេកែតម្រូវ ដោយមានការបន្ថែម និងការកែប្រែផ្សេងៗទៀត។**
បទបង្ហាញនៅទំព័របន្ទាប់ទៀតនេះ មានការគូសបញ្ជាក់ថា មាន <u>សេចក្តីលម្អិតព្រាង</u> នៅក្នុងផ្នែកនេះ។
ការគូសបញ្ជាក់ទាំងនេះ <u>មិនបាន</u> បញ្ជាក់នូវការសរសេរផែនការចប់ឡើយ។

# តើនឹងមានអ្វីខ្លះ នៅក្នុងផែនការ LCAP ព្រាង #1?

## សេចក្តីសង្ខេបរបស់ផែនការ

ផ្នែកនេះគឺផ្តល់ព័ត៌មាន អំពីមន្ទីរអប់រំ ព្រមទាំងព័ត៌មានដែលពាក់ព័ន្ធគ្នា អំពីតម្រូវការចាំបាច់ និងលទ្ធផលសិក្សារបស់សិស្ស។

- ***ព័ត៌មានទូទៅ***
  សេចក្តីពិពណ៌នារបស់មន្ទីរអប់រំមួយ សាលារៀនរបស់ខ្លួន ហើយនិងសិស្សានុសិស្សរបស់ខ្លួន។

- ***ការឆ្លុះបញ្ចាំង៖ ការអនុវត្តការងារប្រចាំឆ្នាំ***
  ការឆ្លុះបញ្ចាំមួយ ទៅលើការអនុវត្តការងារប្រចាំឆ្នាំ ដោយផ្អែកលើការត្រួតពិនិត្យឡើងវិញមួយ
  របស់ក្តារគ្រប់គ្រងរបស់សាលារៀននៃរដ្ឋកាលីហ្វ័រញ៉ា(California School Dashboard) និងទិន្នន័យនៅមូលដ្ឋាន។

- ***ការឆ្លុះបញ្ចាំង៖ ជំនួយបច្ចេកទេស***
  សេចក្តីសង្ខេបនៃការការងាមួយ ដែលកំពុងដំណើរការអនុវត្ត ជាផ្នែកមួយនៃជំនួយបច្ចេកទេស៖ «ជំនួយបែបខុសៗគ្នា»

- ***ជំនួយគាំទ្រ និងកែលម្អដ៏ទូលំទូលាយ***
  មន្ទីរអប់រំមួយ ដោយមានសាលាទាំងឡាយ ដែលបានកំណត់សម្រាប់ទទួលជំនួយគាំទ្រ និងការកែលម្អដ៏ទូលំទូលាយ (CSI)
  និងស្ថិតក្រោមច្បាប់ស្តីសិស្សគ្រប់រូបទទួលជោគជ័យ (Every Student Succeeds Act) គឺឆ្លើយតបទៅនឹង
  ផែនការដើម្បីជួយគាំទ្រដល់សាលារៀននានា។

# តើនឹងមានអ្វីខ្លះ នៅក្នុងផែនការ LCAP ព្រាង #1?

## ការទំនាក់ទំនងពាក់ព័ន្ធដល់ដៃគូធ្វើការអប់រំ

គោលនៅរបស់ផ្នែកនេះ គឺដើម្បីធ្វើឲ្យសហគមន៍ យល់អំពីរបៀបដែលស្ថាប័នអប់រំនៅមូលដ្ឋាន ទំនាក់ទំនងពាក់ព័ន្ធដល់ដៃគូធ្វើការអប់រំ ហើយនិងផលប៉ះពាល់នៃការចូលរួមនោះ។

- **សេចក្តីសង្ខេប**នៃដំណើរការ ដែលត្រូវបានប្រើប្រាស់ដើម្បីទំនាក់ទំនងពាក់ព័ន្ធដល់ដៃគូធ្វើការអប់រំ ក្នុងការបង្កើតនូវផែនការ LCAP នេះ។

  មន្ទីរអប់រំ ត្រូវតែប្រឹក្សាពិគ្រោះ ជាមួយគ្រូបង្រៀន នាយកសាលា អ្នកគ្រប់គ្រង បុគ្គលិកសាលាផ្សេងៗទៀត អង្គភាពចរចារសហជីពនៅមូលដ្ឋាន ហើយនិងសិស្សានុសិស្ស ក្នុងការបង្កើតនូវផែនការ LCAP នេះ។

- រៀបរាប់អំពី **ដំណើរការនៃការចូលរួម** ដើម្បីពាក់ព័ន្ធដល់ដៃគូធ្វើការអប់រំ ក្នុងការបង្កើតនូវផែនការ LCAP នេះ។

- រៀបរាប់អំពី គោលដៅ រង្វាស់ស្ទង់ និងសកម្មភាពទាំងឡាយ ឬការចំណាយដែលដាក់ក្នុងថវិកា ក្នុងផែនការ LCAP ដែល**ត្រូវបានជះឥទ្ធិពល**ដោយ ឬត្រូវបានបង្កើតឡើងក្នុងការឆ្លើយតបទៅនឹងមតិកែលម្អពីដៃគូធ្វើការអប់រំ។

# តើនឹងមានអ្វីខ្លះ នៅក្នុងផែនការ LCAP ព្រាង #1?

## គោលដៅ និង សកម្មភាពទាំងឡាយ

គោលដៅទាំងឡាយគួរតែមានទំនាក់ទំនងគ្នាទៅនឹង អ្វីដែលមន្ទីរគ្រោងនឹងសម្រេច អ្វីដែលមន្ទីរគ្រោងធ្វើ ដើម្បីសម្រេចនូវគោលដៅ ហើយនិងរបៀបដែលមន្ទីរនឹងដឹងថា នៅពេលណាដែលមន្ទីរសម្រេចគោលដៅនោះបាន។

- *គោលដៅជាច្រើន៖*
  ផែនការ LCAP ត្រូវតែឆ្លើតបចំពោះ អាតិភាពទាំងអស់របស់មូលនិធិ LCFF និងរង្វាស់ស្ទង់ដែលពាក់ព័ន្ធគ្នាជាច្រើន។

- *ការវាស់ស្ទង់ និងការរាយការណ៍លទ្ធផលជាច្រើន៖ (មកដល់ពេលនេះ)*
  រង្វាស់ស្ទង់ ដើម្បីតាមដានការវិវត្តលូតលាស់ ឆ្ពោះទៅរកលទ្ធផលដែលបានរំពឹងទុកជាច្រើន

- *ការវិភាគលើគោលដៅ៖*
  ការវិភាគ ថាតើសកម្មភាពដែលបានគ្រោងទុក មានប្រសិទ្ធិភាពឆ្ពោះទៅរកការសម្រេចគោលដៅដែរឬយ៉ាងណា។

- *សកម្មភាពជាច្រើន៖*
  កម្មវិធី និងសេវាកម្មជាច្រើន ដែលត្រូវបានគ្រោងទុកក្នុងថវិកា។ សកម្មភាពមួយចំនួន «កំពុងរួមចំណែកដល់» (កម្មវិធី និងសេវាកម្មជាច្រើន ដែលផ្តល់អត្ថប្រយោជន៍យ៉ាងសំខាន់ ដល់សិស្សគេជ្រើចិញ្ចឹមបណ្តោះអាសន្ន សិស្សដែលគ្មានសារមានចំណូលទាប និង/ឬ សិស្សរៀនភាសាអង់គ្លេស)។

# តើនឹងមានអ្វីខ្លះ នៅក្នុងផែនការ LCAP ព្រាង #1?

## ការបង្កើន ឬ ការពង្រឹងសេវាកម្មទាំងឡាយ សម្រាប់សិស្សគេជ្រើសចិញ្ចឹមបណ្តោះអាសន្ន សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលគ្រួសារមានចំណូលទាប

**នឹងកើតមានក្នុងពេលឆាប់ៗនេះ**

ផ្នែកនេះ ផ្តល់សេចក្តីពិពណ៌នាយ៉ាងទូលំទូលាយ អំពីរបៀបដែលមន្ទីរអប់រំ ដាក់ផែនការក្នុងការបង្កើន ឬពង្រឹងសេវាកម្មទាំងឡាយ សម្រាប់សិស្សគេជ្រើសចិញ្ចឹមបណ្តោះអាសន្ន សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលគ្រួសារមានចំណូលទាប។

ការពន្យល់ល្អិតល្អន់ អំពីរបៀបដែលសកម្មភាពរួមចំណែកទាំងឡាយ ត្រូវបានបង្កើតឡើង ដើម្បី**ឆ្លើយតបទៅនឹងតម្រូវការកំណត់ជាពិសេសទាំងឡាយ** របស់ក្រុមសិស្សដែលកំពុងមានការលំបាកក្នុងការសិក្សាដែលកំពុងត្រូវបានបង្ហាញ៖

- សិស្សគេជ្រើសចិញ្ចឹមបណ្តោះអាសន្ន
- សិស្សដែលគ្រួសារមានចំណូលទាប
- សិស្សរៀនភាសាអង់គ្លេស


ដំណាក់កាលជាបន្ទាប់ទៀត៖
សេចក្តីព្រាងនេះ នឹងត្រូវកែតម្រូវ ដោយមានការបន្ថែម និងការកែប្រែផ្សេៗទៀត។

# គោលដៅ រង្វាស់ស្ទង់ សកម្មភាព និង ភាពស៊ីសង្វាក់គ្នា

# ការដាក់ផែនការ ដើម្បីឲ្យមានភាពស៊ីសង្វាក់គ្នា

## ប្រធានបទជាច្រើននៃផែនការយុទ្ធសាស្ត្រ

ការសិក្សាដែលមានគុណភាពខ្ពស់ សម្រាប់សិស្សទាំងអស់គ្នា
មន្ទីរអប់រំដែលមានសមធម៌ និងសេរីភាព
ការចាប់ដៃគូសហការជាមួយសហគមន៍
បណ្តុះការផ្លាស់ប្តូរដែលមានកំណែទម្រង់







## គោលដៅរបស់ក្រុមប្រឹក្សាភិបាលអប់រំ និងអគ្គនាយកអប់រំ

ជំនាញអានស្ទាត់
ការពន្លឿនការអាន
ជំនាញពិជគណិតស្ទាត់
ការត្រៀមខ្លួនរៀនមហាវិទ្យាល័យ និងអាជីព
*សិស្សដែលចេះធន និងមានចិត្ត*




## គោលដៅ និងវង្វាស់ស្ទង់ របស់ផែនការ

ការរៀបចំផែនការ ដើម្បីឲ្យស្របគ្នាជាមួយនឹងគោលដៅ និងវង្វាស់ស្ទង់ទាំងឡាយរបស់ ផែនការ LCAP ជាមួយនឹងប្រធានបទជាច្រើនរបស់ផែនការយុទ្ធសាស្ត្រ និងគោលដៅជាច្រើនរបស់ ក្រុមប្រឹក្សាភិបាលអប់រំ និងអគ្គនាយកអប់រំ។

